**មណ្ឌលវប្បធម៌ខ្មែរនៅស្វីស វត្តសង្ឃារាម**

**Khmer Kulturzentrum in der Schweiz**

**Centre Culturel Khmer en Suisse**

Kirchgasse 12, 5746 Walterswil SO / Tel 044 363 59 00 / www.khmer-kulturzentrum.ch




# បុណ្យផ្ការស្មីសាមគ្គី

**( Samstag den 21.06.2014)**

ខ្ញុំព្រះករុណា អាត្មាភាព យើងខ្ញុំទាំងអស់គ្នា ជាព្រះសង្ឃ អាចារ្យគណៈកម្មការ នៃមណ្ឌល-វប្បធម៌ខ្មែរ វត្ត **សង្ឃារាម** មូលមតិគ្នាជាឯកច្ឆន្ទ ប្រារព្ធធ្វើកម្មវិធីបុណ្យ **ផ្ការស្មីសាមគ្គី** មួយ ដើម្បីជួយទ្រទ្រង់ឧបត្ថម្ភបន្ថែមដល់មណ្ឌលវប្បធម៌ វត្តខ្មែរយើងឱ្យមានចិរភាព ជាអង្វែង។

អាស្រ័យហេតុ ដូចបានប្រគេន និងជម្រាបជូនខាងលើនេះ ខ្ញុំព្រះករុណា អាត្មាភាព យើងខ្ញុំទាំង អស់គ្នា មានសេចក្ដីសោមនស្សរីករាយ សូមអារាធនានិមន្ត និងអញ្ជើញ ព្រះតេជគុណ អស់លោក លោកស្រី ព្រមទាំងពុទ្ធបរិស័ទទាំងអស់ ចូលរួមក្នុងកម្មវិធីបុណ្យនេះ ដើម្បីរួមចំណែកទ្រទ្រង់វិស័យ វប្បធម៌ ប្រពៃណី សាសនាខ្មែរយើង នៅនាទឹកដីទីបីនេះ និងអនុមោទនាយកនូវកុសលផលបុណ្យរៀង ៗ ខ្លួនផង ដើម្បីញុំាងកម្មវិធីបុណ្យឱ្យមានភាពកុះករ ប្រកបដោយធម្មៈផង កុំបីខានឡើយ។

## កម្មវិធីបុណ្យ

ថ្ងៃសៅរ៍ ៩ រោច ខែជេស្ឋ ឆ្នាំមមី ឆស័ក ព.ស.២៥៥៨ ដែលត្រូវនឹងថ្ងៃទី ២១ មិថុនា គ.ស.២០១៤ នាអាស័យដ្ឋានមណ្ឌលវប្បធម៌ខ្មែរ វត្ត សង្ឃារាម Kirchgasse 12, 5746 Walterswil

ម៉ោង ១០ និង ១៥ នាទី ជួបជុំពុទ្ធបរិស័ទជិតឆ្ងាយ ធ្វើបទនមស្សការ សមាទានសីល រាប់បាត្រ និងវេរចង្ហាន់បិណ្ឌបាតថ្វាយដល់ព្រះភិក្ខុសង្ឃ

ម៉ោង ១២ និង ០០ នាទី ពុទ្ធបរិស័ទទទួលទានភោជនាហារថ្ងៃត្រង់

ម៉ោង ១៣ និង ៣០ នាទី ដង្ហែផ្កាប្រាក់ ជុំវិញវត្ត សង្ឃារាម យកមកវេរប្រគេនព្រះសង្ឃ

ម៉ោង ១៤ និង ០០ នាទី ធម្មទេសនា និងសរុបបច្ច័យផ្កាប្រាក់

បញ្ជាក់ សូមពុទ្ធបរិស័ទមេត្តានាំយកចង្ហាន់សម្រាប់រាប់បាត្រប្រគេនព្រះសង្ឃផង ។

ពត៌មានលម្អិត សូមទាក់ទងមកកាន់វត្ត តាមរយៈទូរស័ព្ទ **(+41) 044 363 59 00**

